ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១៦ សកបយ

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និង ការបញ្ជាក់ភាពជាតំណាង
## របស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត

ផ្អែកតាមច្បាប់ស្តីពីការងារ ប្រកាសលេខ២៧៧សកបយ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០០ ស្តីពីការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងប្រកាសលេខ៣០៥សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត នៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាពដើម្បីចុះអនុសញ្ញារួម នៅថ្នាក់សហគ្រាស គ្រឹះស្ថាន ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដល់សហព័ន្ធសហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និងនិយោជកទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តន៍នៃច្បាប់ស្តីពីការងារ អោយបានជ្រាបថា :

I-ក្រសួងទើបបានបង្កើតការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ នៅចំពោះនាយកដ្ឋានអធិការកិច្ចការងារ កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០២ តាមប្រកាសលេខ២២២ សកបយ.។ ការិយាល័យនេះមានភារកិច្ចជាពិសេសក្នុងការទទួលសំណុំលិខិត និងចាត់ចែងការងារនៃការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ ការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត ការចុះបញ្ជិកាកំណត់ហេតុបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក។

ការបង្កើតការិយាល័យថ្មីនេះ គឺក្នុងគោលបំណងសម្រួលដល់ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាង របស់សហជីពអោយបានងាយស្រួល និងឆាប់រហ័ស។

II-<u>បែបបទចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត :</u>

១-<u>ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ</u>

ស្ថាបនិកនៃសហជីពកម្មករនិយោជិត និងសមាគមនិយោជកត្រូវយកសំណុំលិខិតស្នើសុំចុះបញ្ជិកាអង្គការវិជ្ជាជីវៈ (សហជីព ឬ សមាគមនិយោជក) ទៅដាក់ជូនការិយាល័យទំនាក់ទំនងវិជ្ជាជីវៈនៃនាយកដ្ឋានអធិការកិច្ចការងារ អាសយដ្ឋានលេខ២៨ វិថីសម្តេចព្រះពុទ្ធលិខិតអ៊ុក (ផ្លូវលេខ១៨៤) សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ៤

មិនបានទៅជួបមន្ត្រីនៃការិយាល័យទំនាក់ទំនងវិជ្ជាជីវៈទេ មន្ត្រីនោះត្រូវផ្ញើសំណុំលិខិតនោះត្រឡប់ទៅម្ចាស់ដើមវិញ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា កំណត់ថិរវេលាអតិបរមា ២ ខែ សំរាប់រៀបចំដំណើរការការងារទាំងពីរនេះ តាមនីតិវិធីច្បាប់ ។ ថិរវេលា២ខែនេះនឹងត្រូវពន្យា ក្នុងករណីមានការប្តឹងជំទាស់តវ៉ា ឬ ហេតុផលចាំបាច់ណាមួយជាយថាហេតុ ដែលទាមទារអោយមានការងារបន្ត ។

**IV-<u>នីតិវិធីនៃការតវ៉ាចំពោះការយឺតយ៉ាវនៃការដោះស្រាយសំណុំរឿង :</u>**

ក្នុងករណីពិនិត្យឃើញថា មានការយឺតយ៉ាវក្នុងការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការចេញលិខិតបញ្ជាក់ពីភាពជាតំណាងអង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត ខុសពីថិរវេលាខាងលើ ម្ចាស់សំណុំរឿងអាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅនាយកដ្ឋានអធិការកិច្ចការងារ ។ ក្រោយពីដាក់ពាក្យតវ៉ានេះរយៈពេល២សប្តាហ៍ បើគ្មានការបំភ្លឺសមស្របពីនាយកដ្ឋានអធិការកិច្ចការងារទេ ម្ចាស់សំណុំរឿងអាចធ្វើការតវ៉ាដោយផ្ទាល់ទៅអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ ទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសង្ឃឹមយ៉ាងមុតមាំថា សហពន្ធ័ សហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និង និយោជកទាំងអស់នឹងខិតខំសហការជាមួយក្រសួងដើម្បីអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

<u>ចម្លងជូន</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
-សាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងលេខ:...១៦......សកបយ.

ចុះថ្ងៃទី២៦...ខែ.កញ្ញា ឆ្នាំ២០០២ ស្តីពីសំណើសុំការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ

និងការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត

"ពាក្យស្នើសុំ"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សហព័ន្ធសហជីព...................

សហជីព......................

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០២

ប្រធានសហជីព.....(ឈ្មោះ សហជីព).............

គោរពជូន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**កម្មវត្ថុ** : សំណើសុំភាពជាតំណាង☐ ភាពជាតំណាងបំផុត☐របស់អង្គការវិជ្ជាជីវៈនៃកម្មករ និយោជិត

**យោង** :-ច្បាប់ស្តីពីការងារ

-ប្រកាសលេខ៣០៥សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ នៃកម្មករនិយោជិតនៅថ្នាក់សហគ្រាសគ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់ សហគ្រាស គ្រឹះស្ថាន

-សេចក្តីជូនដំណឹងលេខ...........សកបយ. ចុះថ្ងៃទី..........ខែ............ឆ្នាំ២០០២ ស្តីពីការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករ និយោជិត ។

សេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីបានជ្រាបថា ដើម្បីបានភាពជាតំណាងក្នុងការចរចាជាសមូហភាព ការចុះអនុសញ្ញារួម និងការចានាដោះស្រាយបញ្ហាផ្សេងៗជាមួយនិយោជក ខ្ញុំសូមគោរពស្នើសុំឯកឧត្តមរដ្ឋមន្ត្រីមេត្តាបញ្ជាក់ពីភាពជាតំណាង☐ភាពជាតំណាងបំផុត☐របស់សហជីពខ្ញុំបាទ/នាងខ្ញុំ ។

ពត៌មានអំពីសហជីពមានដូចខាងក្រោមនេះ:

១-ឈ្មោះអង្គការវិជ្ជាជីវៈ.......................................................................

២-បានចុះបញ្ជិកាលេខ.................សកបយ. ចុះថ្ងៃទី.....................................

៣-ក្របខណ្ឌ ភូមិសាស្ត្រ ឬ វិជ្ជាជីវៈរបស់អង្គការវិជ្ជាជីវៈ និងវិជ្ជាជីវៈ

-ឈ្មោះសហគ្រាស គ្រឹះស្ថានៈ.................................................................................................

-ទូទាំងសហគ្រាស គ្រឹះស្ថាន ☐

-វិជ្ជាជីវៈខ្លះនៃសហគ្រាស គ្រឹះស្ថាន☐ បរិយាយៈ.........................................................................

.............................................................................................................................................។

៤-ចំនួនសមាជិកសហជីព.......................នាក់ និងចំនួនកម្មករសរុប.......................នាក់ (ក្នុងក្របខណ្ឌ ភូមិសាស្ត្រ ឬ វិជ្ជាជីវៈរបស់អង្គការវិជ្ជាជីវៈ និងវិជ្ជាជីវៈ)

៥-ការបង់ភាគទានៈ

-បង់ដោយផ្ទាល់ដៃ ☐ ចំនួន....................នាក់ ស្មើនឹង.............ភាគរយនៃសមាជិក

-បង់តាមរយៈនិយោជក ☐ ចំនួន....................នាក់ ស្មើនឹង.............ភាគរយនៃសមាជិក

៦-កម្មវិធីការងាររបស់សហជីពៈ

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

៧-ជូនភ្ជាប់មកជាមួយនូវៈ

-ច្បាប់ថតចម្លងវិញ្ញាបនបត្រចុះបញ្ជិកា ចំនួន ០១ច្បាប់

-.............................................................................................................................

-.............................................................................................................................។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ ខ្ញុំសូមស្នើសុំសេចក្តីបញ្ជាក់ដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រី ដើម្បីបានភាពស្របច្បាប់ក្នុងការអនុវត្តន៍តទៅ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រ អំពីខ្ញុំ។

**ប្រធានសហជីព**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០២

បានឃើញ និងសូមស្នើសុំសេចក្តីបញ្ជាក់ដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រី

ប្រធានសហព័ន្ធសហជីព

*(ករណីដែលសហជីពនោះជាសមាជិករបស់សហព័ន្ធសហជីពណាមួយ)*